ជ័យជម្នះទ្រង់ ជាជ័យជម្នះរបស់យើង

ខណៈដែលយើងកំពុងទន្ទឹងរង់ចាំ ថ្ងៃដែលកូនកំលោះនៃស្ថានសួគ៌របស់យើង គឺព្រះយេស៊ូវគ្រីស្ទយាងត្រឡប់មកវិញ ដើម្បីរំដោះយើងយើងចេញពីសម័យកាលដ៏អាក្រក់នេះ យើងត្រូវបានត្រាស់ហៅឲ្យញែកចេញពីលោកិយ។ នៅពេលព្រះគម្ពីរប្រើពាក្យ «លោកិយ» ជាទូទៅ វាមិនមែនសំដៅលើផែនដី ឬមនុស្សទាំងអស់ទេ ប៉ុន្តែ សំដៅលើប្រព័ន្ធរបស់លោកិយ ដូចជារបៀបរបបនយោបាយ និងសង្គម ដែលបដិសេធព្រះ ដែលត្រូវបានគ្រប់គ្រងដោយសាតាំង ហើយត្រួតត្រាចិត្តគំនិត និងទម្លាប់នៃមនុស្សដែលមិនទាន់បានសង្គ្រោះ។ តាមរយៈការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ព្រះជាម្ចាស់បានធានាជ័យជម្នះចុងក្រោយលើអារក្ស។ សាតាំង អាចគ្រប់គ្រងប្រព័ន្ធលោកិយនេះ ប៉ុន្តែ រជ្ជកាលរបស់វាកំពុងខិតជិតដល់ទីបញ្ចប់ហើយ។ ការប្រោសលោះយើង និងសិរីល្អរបស់ព្រះ នឹងស្ថិតស្ថេរអស់កល្បជានិច្ច។

ដោយមានការយល់ដឹងនេះ យើងត្រូវចែករំលែកពន្លឺ និងសេចក្តីស្រឡាញ់របស់ព្រះទៅកាន់លោកិយ ប៉ុន្តែ មិនត្រូវធ្លាក់ចូលទៅក្នុងការស្រឡាញ់ប្រព័ន្ធលោកិយ ឬស្វែងរកឲ្យបានការស្រឡាញ់ពីលោកិយនោះឡើយ។ ដោយផ្តោតលើផ្ទះស្ថានសួគ៌របស់យើង យើងត្រូវប្រដាប់ខ្លួនដោយភាពបន្ទាបខ្លួន។ យើងត្រូវដោះចោលគ្រប់ការខិតខំប្រឹងប្រែង និងបំណងចិត្តដែលស្វែងរកតែប្រយោជន៍ផ្ទាល់ខ្លួន ព្រោះការទាំងនេះគ្រាន់តែបង្កើនអំនួតរបស់យើង ដែលជាទស្សនៈដ៏គ្រោះថ្នាក់ ធ្វើឲ្យភ្នែកខាងវិញ្ញាណរបស់យើងងងឹត មិនអាចមើលឃើញការបោកបញ្ឆោតរបស់សាតាំងបាន ហើយធ្វើឲ្យយើងក្លាយជាមនុស្សងាយរងគ្រោះ។

ជាដំបូង និងសំខាន់បំផុត យើងត្រូវតែកាន់ខ្ជាប់នឹងឈើឆ្កាង។ ឈើឆ្កាងគឺជាឧបករណ៍ដដែល ដែលប្រកាសទោសប្រហារជីវិតលើសាតាំង និងធានាការសង្គ្រោះរបស់យើង តាមរយៈជ័យជម្នះរបស់ព្រះគ្រីស្ទ ជាជ័យជម្នះដែលនឹងត្រូវបានសម្រេចយ៉ាងពេញលេញសម្រាប់យើង នៅក្នុង «ចម្បាំងគ្រប់សម័យកាល»។

ការអធិស្ឋានសុំជំនួយ

នៅពេលដែលយើង ទទួលស្គាល់ភាពងាយរងគ្រោះរបស់យើង ចំពោះការបោកបញ្ឆោត និងតម្រូវការរបស់យើង ចំពោះអំណាចដែលមករកយើងតាមរយៈយញ្ញបូជារបស់ព្រះយេស៊ូវនៅលើឈើឆ្កាង ចូរយើងងាកទៅរកព្រះអម្ចាស់ឥឡូវនេះ ដើម្បីសុំជំនួយដ៏អស្ចារ្យពីទ្រង់ក្នុងការប្រយុទ្ធប្រឆាំងនឹងការបោកបញ្ឆោត។

ព្រះអម្ចាស់យេស៊ូវអើយ! យើងខ្ញុំប្រាថ្នាយ៉ាងស្មោះអស់ពីចិត្ត ឲ្យរួចផុតពីអាកប្បកិរិយានៃអំនួត និងការស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន ដែលអាចធ្វើឲ្យយើងខ្ញុំងងឹតភ្នែក ចំពោះការបោកបញ្ឆោតគ្រប់ ទម្រង់។ សូមអត់ទោសឲ្យយើងខ្ញុំចំពោះទំនោរទាំងនោះផង។

ឥឡូវនេះ យើងខ្ញុំងាកទៅរកឫទ្ធានុភាពនៃឈើឆ្កាង ជាកន្លែងដែលទ្រង់បានបង្ហូរ ព្រះលោហិតរបស់ទ្រង់ ដើម្បីសង្គ្រោះ និងការពារយើងខ្ញុំពីគម្រោងការអាក្រក់ទាំងអស់របស់សត្រូវ។ យើងខ្ញុំអំពាវនាវដល់ព្រះនាមរបស់ទ្រង់ គឺព្រះយេស៊ូវ និងអំណាចនៃព្រះបន្ទូលរបស់ទ្រង់ ដើម្បីការពារយើងខ្ញុំពីការបោកបញ្ឆោតគ្រប់ប្រភេទ និងអាចឲ្យយើងខ្ញុំដើរក្នុងសេចក្តីពិតរបស់ទ្រង់។

អាម៉ែន!

ស្វែងយល់ពីព្រះបន្ទូលព្រះឲ្យកាន់តែស៊ីជម្រៅ

សេចក្តីបង្រៀនជាលិខិតរបស់លោកដេរេក ព្រីនស៍ អាចទាញយកដោយឥតគិតថ្លៃពីគេហទំព័ររបស់យើង www.derekprince.com/km-kh/resources

ស្កេន QR ដើម្បីចូលគេហទំព័រ DPM-KH

ព័ន្ធកិច្ច ដេរេក ព្រីនស៍ កម្ពុជា
Facebook / Youtube: Derek Prince Ministries Cambodia | www.derekprince.com/km-kh

ISSUE #092

លោកដេរេក ព្រីនស៍៖ សេចក្តីបង្រៀនជាលិខិត
ការយល់ដឹងពីព្រះគម្ពីរ ដើម្បីផ្លាស់ប្រែជីវិតរបស់អ្នក

Free COPY

ចម្បាំងគ្រប់សម័យកាល

ផ្នែកទី ១៖ គ្រោះថ្នាក់នៃការបោកបញ្ឆោត

នៅក្នុងសៀវភៅ ការការពារពីការបោកបញ្ឆោត ដែលបានកែសម្រួលថ្មី ហើយឥឡូវនេះត្រូវបានចេញផ្សាយក្រោមចំណងជើងថា ចម្បាំងគ្រប់សម័យកាល លោក ដេរេក ព្រីនស៍ បានព្រមានអំពីគ្រោះថ្នាក់ដ៏ធំបំផុត ដែលគ្រីស្ទបរិស័ទនឹងត្រូវប្រឈមមុខនៅគ្រាចុងក្រោយបង្អស់។

នៅក្នុងផ្នែកទីមួយ ក្នុងចំណោមផ្នែកទាំងបីរបស់យើងពីសៀវភៅ «ចម្បាំងគ្រប់សម័យកាល» យើងនឹងពិនិត្យមើលបញ្ហាដ៏សំខាន់នេះ៖ *គ្រោះថ្នាក់នៃការបោកបញ្ឆោត*។

ការព្រមានដែលត្រូវយកចិត្តទុកដាក់

ព្រះយេស៊ូវ បានផ្តល់ការព្រមានយ៉ាងច្បាស់ លាស់អំពីការបោកបញ្ឆោត តាមរយៈការបង្ហាញខ្លួនក្លែងក្លាយ ដែលនឹងកើតឡើងនៅគ្រាចុងក្រោយ។ ការព្រមានទាំងនេះ គឺជាចំណុចស្នូលនៃសង្គ្រាមខាងវិញ្ញាណ ដែលយើងកំពុងប្រឈមមុខ ក្នុង *ចម្បាំងគ្រប់សម័យកាល*។

ការព្រមានចំនួនបួន ត្រូវបានកត់ត្រានៅក្នុងខគម្ពីរ ២១ខ នៅក្នុងកណ្ឌគម្ពីរម៉ាថាយ។ ដំបូងនៅក្នុងម៉ាថាយ 24:4 ព្រះយេស៊ូវ បានព្រមានយើងថា៖ *«ចូរប្រយ័ត ក្រែងអ្នកណានាំអ្នករាល់គ្នាឲ្យវង្វេង»*។ ក្នុងខ 5 ទ្រង់បានថ្លែងទំនាយថា

«ដ្បិតនឹងមានមនុស្សជាច្រើន យកឈ្មោះខ្ញុំមកនិយាយថា ខ្ញុំនេះជាព្រះគ្រីស្ទ ព្រះមេស្ស៊ី ហើយអ្នកទាំងនោះនឹងនាំមនុស្សជាច្រើនឲ្យវង្វេងចេញផង»។ នៅក្នុងខ 11 ទ្រង់បានព្រមានថា៖ *«ក៏នឹងមានហោរាក្លែងក្លាយជាច្រើនកើតឡើង នាំឲ្យមនុស្សជាច្រើនវង្វេងដែរ»*។ ជាចុងក្រោយនៅខទី 24 ទ្រង់បានសរុបសេចក្តីមកថា៖ *«ដ្បិតនឹងមានព្រះគ្រីស្ទ ព្រះមេស្ស៊ី ក្លែង ហើយហោរាក្លែងកើតឡើង គេនឹងធ្វើទីសំគាល់យ៉ាងធំ ហើយនឹងការ អស្ចារ្យ ដើម្បីនឹងនាំទាំងពួកអ្នករើសតាំងឲ្យវង្វេងផង បើសិនជាបាន»*។

មិនត្រូវមើលស្រាល នូវការព្រមានទាំងនេះឡើយ។ អ្នកណាដែលមិនអើពើចំពោះការព្រមានទាំងនេះ គឺកំពុងប្រឈមនឹងគ្រោះថ្នាក់ដល់ព្រលឹងរបស់ខ្លួនឯង។

ការបោកបញ្ឆោតមិនមែនជាជំងឺ ភាពក្រីក្រ ឬការបៀតបៀនទេ វាគឺជាគ្រោះថ្នាក់ដ៏ធំបំផុតតែមួយដែលយើងប្រឈមមុខ នៅគ្រាចុងក្រោយ ហើយវាគឺជាសមរភូមិចុងក្រោយសម្រាប់យើងនៅក្នុង *ចម្បាំងគ្រប់សម័យកាល*។

បញ្ហានៃចិត្ត

អ្នកណាដែលបដិសេធថា ខ្លួនមិនងាយរងការបោកបញ្ឆោត នោះគាត់កំពុងត្រូវបានបោកបញ្ឆោតរួចហើយ ពីព្រោះព្រះយេស៊ូវបានទាយទុកជាមុនហើយព្រះអង្គមិនដែលខុសឡើយ។ ចិត្តរបស់យើង មិនអាចសម្គាល់សេចក្តីពិតដោយខ្លួនឯងបានទេ។

សុភាសិត 28:26 *«អ្នកណាដែលទីពឹងតែចិត្តខ្លួនឯង នោះជាអ្នកល្ងីល្ងើហើយ»* ។ យើងមិនត្រូវធ្វើជាមនុស្សល្ងីល្ងើ ដោយទុកចិត្តលើចិត្តរបស់ខ្លួនឡើយ។ អ្វីក៏ដោយដែលចិត្តរបស់យើងប្រាប់យើង គឺមិនគួរឱ្យទុកចិត្តបានទេ ដូចដែលគម្ពីរយេរេមា 17:9 បានបញ្ជាក់ថា៖ *«ឯចិត្តជាគ្រឿងបញ្ឆោតលើសជាងទាំងអស់ ហើយក៏អាក្រក់ហួសល្បត់ផង តើអ្នកណានឹងអាចស្គាល់បាន»*។ ក្នុងភាសាហេព្រើរ ពាក្យ «គ្រឿងបញ្ឆោត» គឺសកម្ម មិនមែនអកម្មទេ។ មានន័យថា ចិត្តមិនមែនត្រូវបានបញ្ឆោតទេ ប៉ុន្តែ ចិត្តជាអ្នកបោកបញ្ឆោត ដោយនាំយើងឲ្យវង្វេងផ្លូវ។

តើចុងបញ្ចប់ជាអ្វី?

វាក៏សំខាន់ផងដែរ ដែលយើងត្រូវដឹងថាទីសម្គាល់និងការអស្ចារ្យ មិនមែនជាការធានា ឬកំណត់សេចក្តីពិតឡើយ។ សេចក្តីពិតត្រូវបានបង្កើតឡើងរួចហើយ និងមិនផ្លាស់ប្តូរឡើយ។ ព្រះបន្ទូលរបស់ព្រះ គឺជាសេចក្តីពិត។ ក្នុងគម្ពីរ យ៉ូហាន 17:17 ព្រះយេស៊ូវ បានអធិស្ឋានទៅកាន់ព្រះវរបិតាថា៖ *«ឯសេចក្តីពិត គឺជាព្រះបន្ទូលរបស់ទ្រង់»*។ អ្នកសរសេរទំនុកតម្កើងបានប្រកាសថា៖ *«ព្រះបន្ទូលទ្រង់បានតាំងនៅស្ថានសួគ៌ ជារាបដល់អស់កល្បជានិច្ច»* (ទំនុកតម្កើង119:89)។ គ្មានព្រឹត្តិការណ៍ណាមួយលើផែនដី ទោះជាធម្មជាតិ ឬអធិធម្មជាតិក៏ដោយ អាចផ្លាស់ប្តូរទីសម្គាល់ ឬអក្សរតូចបំផុតនៅក្នុងព្រះបន្ទូលរបស់ព្រះបានឡើយ។

ទីសម្គាល់ពិតបញ្ជាក់ពីសេចក្តីពិត ទីសម្គាល់មិនពិតបញ្ជាក់ពីការកុហក។ មានគ្រីស្ទបរិស័ទជាច្រើនសន្មត់ថា គ្រប់ទាំងទីសម្គាល់នៃការអស្ចារ្យទាំងអស់សុទ្ធតែមកពីព្រះ ដោយភ្លេចថា សាតាំង ឬអារក្ស ក៏មានសមត្ថភាពក្នុងការធ្វើទីសម្គាល់ និងការអស្ចារ្យផងដែរ។ លោកសាវ័ក ប៉ុល ក៏បានសរសេរនៅក្នុងសំបុត្រទីពីររបស់គាត់ ទៅកាន់ពួកជំនុំថែសាឡូនិច្ចថា៖

> *អាទទឹងច្បាប់នោះនឹងមកទាំងធ្វើការ ដូចជាអារក្សសាតាំង ដោយនូវគ្រប់ទាំងឫទ្ធិ ទីសំគាល់ នឹងការអស្ចារ្យដ៏កំភូត ហើយដោយគ្រប់ទាំងសេចក្តីឆបោករបស់សេចក្តីទុច្ចរិត ក្នុងពួកអ្នកដែលត្រូវវិនាស ដោយព្រោះគេមិនព្រមស្រឡាញ់ដល់សេចក្តីពិត ដើម្បីឲ្យគេបានសង្គ្រោះនោះទេ ហេតុនោះបានជាព្រះ ទ្រង់នឹងឲ្យសេចក្តីខុសឆ្គងមក បណ្តាលឲ្យគេជឿតាមសេចក្តីភូតភរវិញ ដើម្បីឲ្យអស់មនុស្សណាដែលមិនជឿតាមសេចក្តីពិត គឺពេញចិត្តនឹងសេចក្តីទុច្ចរិត នោះបានជាប់មានទោសវិញ។*
> *(២ថែស្សាឡូនិច្ច 2:9–12)*

អត្ថបទគម្ពីរនេះបង្ហាញយ៉ាងច្បាស់ថា ពិតជាមានទីសម្គាល់ និងអំណាចអស្ចារ្យក្លែងក្លាយ។ ដូច្នេះព្រឹត្តិការណ៍ណាមួយ មិនអាចត្រូវបានទទួលស្គាល់ថាជាការពិត ដោយគ្រាន់តែវាត្រូវបានចាត់ទុកថាជាការបង្ហាញអំណាចអស្ចារ្យប៉ុណ្ណោះទេ។ សូមមើលត្រឡប់ទៅកណ្ឌគម្ពីរនិក្ខមនំ មានការអស្ចារ្យជាច្រើនដែលលោកម៉ូសេបានធ្វើ តតាំងជាមួយនឹងគ្រូមន្តអាគម និងគ្រូអាបធ្មប់របស់ផារ៉ោន (សូមមើលនៅក្នុង និក្ខមនំ 7:11–23) ។ ដំបងរបស់លោកម៉ូសេ បានក្លាយទៅជាសត្វពស់ ហើយលេបសត្វពស់ ដែលចេញពីដំបងវេទមន្តរបស់គ្រូធ្មប់នោះ។ ប៉ុន្តែ ការពិតបានបង្ហាញថា សាតាំងអាចផ្តល់អំណាចទៅកាន់បុគ្គលណាម្នាក់ ដើម្បីសម្តែងការអស្ចារ្យជាក់លាក់ណាមួយ។


អស់អ្នកដែលទទួលយកការកុហករបស់សាតាំងក៏អាចធ្វើដូច្នេះបានដែរ *«ដោយព្រោះគេមិនព្រមស្រឡាញ់ដល់សេចក្តីពិត... ហេតុនោះបានជាព្រះ ទ្រង់នឹងឲ្យសេចក្តីខុសឆ្គងមក»*

(២ថែស្សាឡូនិច្ច 2:10–11)។ នេះគឺជាសេចក្តីថ្លែងការណ៍ដ៏គួរឱ្យភ័យខ្លាចបំផុតមួយ ក្នុងព្រះគម្ពីរ។ ប្រសិនបើព្រះឲ្យសេចក្តីខុសឆ្គងមកនោះច្បាស់ណាស់ថាយើងនឹងត្រូវបានបញ្ឆោត។ ការថ្កោលទោសកើតឡើងចំពោះអ្នកដែល *«មិនជឿតាមសេចក្តីពិត គឺពេញចិត្តនឹងសេចក្តីទុច្ចរិតនោះបានជាប់មានទោសវិញ»* (ខ12) ។

មាត្រដ្ឋានចុងក្រោយបំផុត

វិធីតែមួយគត់ដើម្បីដឹងថា ទីសម្គាល់ ឬការអស្ចារ្យណាមួយ ជាការពិត ឬមិនពិត គឺត្រូវវាស់វែងវាជាមួយនឹងសេចក្តីពិតគឺជាព្រះបន្ទូលរបស់ព្រះ។ នៅក្នុងយ៉ូហាន ៨:៣២ ព្រះយេស៊ូវមានបន្ទូលថា *«អ្នករាល់គ្នានឹងស្គាល់សេចក្តីពិត ហើយសេចក្តីពិតនោះ នឹងប្រោសឲ្យអ្នករាល់គ្នាបានរួច»* ។ អត្ថបទព្រះគម្ពីរ គឺជាមាត្រដ្ឋានតែមួយគត់ សម្រាប់កំណត់ថា អ្វីជាសេចក្តីពិត ឬក្លែងក្លាយ។ យើងត្រូវបានបង្គាប់ឲ្យ *«លមើលគ្រប់ទាំងអស់ ហើយកាន់ខ្ជាប់តាមសេចក្តីដែលត្រឹមត្រូវ»*។ (១ថែស្សាឡូនិច្ច 5:21)

គម្ពីរវិវរណៈ បានសន្យាអំពីលំដាប់ជាក់លាក់នៃទីសម្គាល់ និងការអស្ចារ្យលើសពីវិស័យធម្មជាតិ ដែលជាសញ្ញាបង្ហាញអំពីគ្រាចុងក្រោយបង្អស់។ ភារកិច្ចរបស់យើង ក្នុងសមរភូមិនៃសម័យកាលនេះ គឺត្រូវអនុវត្តការសង្កេតស្គាល់ខាងវិញ្ញាណ ខណៈដែលយើងទន្ទឹងរង់ចាំ ថ្ងៃនៃការជំនុំជម្រះ ដោយការពារខ្លួនពីយុទ្ធសាស្ត្រ និងល្បិចកលរបស់អារក្ស ហើយកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវពួកជំនុំដ៏ពិត ដែលជាកូនក្រមុំនៃព្រះគ្រីស្ទ។



តាមរយៈ ការសុគត និងការរស់ឡើងវិញរបស់ ព្រះយេស៊ូវ ព្រះជាម្ចាស់បានប្រទាន ជ័យជម្នះចុងក្រោយ លើអារក្សសាតាំង។